## ភាគីពាក់ព័ន្ធក្នុងការងារ គ្រប់គ្រងគ្រោះមហន្តរាយ

- **សហគមន៍** ៖ ជាអ្នកឆ្លើយតបដំបូងគេនៅពេលមានគ្រោះមហន្តរាយកើតឡើងនៅក្នុងសហគមន៍របស់ខ្លួន និងជាអ្នកចងក្រងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់សហគមន៍។
- **ក្រសួងជំនាញ/ពាក់ព័ន្ធ** ៖ ដូចមានចែងក្នុងអនុក្រិត្យរបស់រាជរដ្ឋាភិបាល លេខ ២០ សសរ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦។
- **កាកបាទក្រហមកម្ពុជា** ៖ ជាជំនួយការឱ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ ជាភាគីពាក់ព័ន្ធដ៏សំខាន់ និងជាអ្នកផ្តល់សេវាកម្មក្នុងការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- **វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ**
- **អង្គការជាតិ/អន្តរជាតិ** ៖ ជាអ្នកសម្របសម្រួល និងពង្រឹងកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឱ្យកាន់តែមានប្រសិទ្ធភាព ដែលមានដូចជា ៖

ក្រុមធ្វើសកម្មភាពរួមកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (JAG)

វេទិកាឆ្លើយតបមនុស្សធម៌ (HRF)

សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (IFRC)

មជ្ឈមណ្ឌលសម្របសម្រួលជំនួយមនុស្សធម៌លើការងារគ្រប់គ្រងគ្រោះមហន្តរាយនៅអាស៊ាន (AHA Center)

ONE ASEAN ONE RESPONSE

ប្រព័ន្ធកម្រង The Cluster system

ភ្នាក់ងារអង្គការសហប្រជាជាតិ

UN agencies


**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)**

អាស័យដ្ឋាន ៖ អាគាររដ្ឋបាលសាធារណៈថ្មី

ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥)២៣ ៨៦៤ ២៩៨

ទូរសារ : (៨៥៥)២៣ ៨៨២ ០៤៥

អ៊ីម៉ែល: administration@ncdm.gov.kh




# ក្របខណ្ឌការងារ គ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា

2017

International Federation of Red Cross and Red Crescent Societies

# ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ បានចូលជាធរមាននៅក្នុងឆ្នាំ២០១៥។ គោលបំណងច្បាប់នេះសម្រាប់កសាងភាពធន់នៅកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់លើការឆ្លើយតប ការសមាហរណកម្មវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងអាណត្តិរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បីកំណត់នូវគោលការណ៍កាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

**មាត្រា ២**

ច្បាប់នេះមានគោលដៅដូចតទៅ ៖
- ត្រៀមបង្ការ បន្សាំ កាត់បន្ថយគ្រោះថ្នាក់មុនពេលមានគ្រោះមហន្តរាយ ដែលបង្កដោយធម្មជាតិ ឬមនុស្ស
- ឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ
- ស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ



## វដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ




ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ផ្តោតលើវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ រួមមាន ការការពារ និងកាត់បន្ថយ ការត្រៀមបង្ការ ការឆ្លើយតបនិងសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ (មាត្រា១០ដល់មាត្រា១៣)។

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម)**
គ.ជ.គ.ម ត្រូវបានបង្កើតឡើង ជាសេនាធិការឱ្យរាជរដ្ឋាភិបាល **ដើម្បីដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារ**គ្រប់គ្រងគ្រោះមហន្តរាយ (មាត្រាទី ៦)។

**គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ** ដែលរួមមានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ (មាត្រា ៩)។

**នៅពេលដែលមានគ្រោះមហន្តរាយកើតឡើងតែនៅក្នុងដែនរដ្ឋបាលឃុំ** សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្តណាមួយ ត្រូវចាត់ទុកជាការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង ខេត្ត។

ក្នុងករណីដែលវិសាលភាពនៃគ្រោះមហន្តរាយមានទំហំហួសពីសមត្ថភាព និងលទ្ធភាពឆ្លើយតបរបស់ខ្លួន **គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវ ត្រូវជូនដំណឹងជាបន្ទាន់ទៅគ.ជ.គ.ម** ដើម្បីសុំយោបល់ និងការជួយអន្តរាគមន៍ ឬចលនាធនធានមនុស្សធម៌ ដើម្បីឆ្លើយតបតាមការជាក់ស្តែង។

គ.ជ.គ.ម ត្រូវជួបប្រជុំគ្រប់ភាគីពាក់ព័ន្ធ ពិភាក្សាអំពីការឆ្លើយតប លើកជាសំណើ និងវិធានការចាំបាច់នានាជូនដល់រាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តប្រកាសអំពីគ្រោះមហន្តរាយ និងចាត់វិធានការនានាទាក់ទងនឹងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ។ **ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល ត្រូវចូលរួមក្នុងប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយតាមការស្នើសុំ** របស់អាជ្ញាធរមានសមត្ថកិច្ច និង គ.ជ.គ.ម។

គ.ជ.គ.ម គឺជាអ្នកដឹកនាំសម្របសម្រួល និងអនុវត្តកិច្ចសហប្រតិបត្តិការ កិច្ចសហការ និង**ជំនួយជាថវិកា ធនធាន និងសម្ភារៈអន្តរជាតិ**